# ជំពូកទី ៧

Draft

# ជំពូកទី ៧: ផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប) ផ្តល់ជាមាតិាសំរាប់ វិធានការកាត់បន្ថយ ការត្រួតពិនិត្យតាមដាន និងការធ្វើអធិការកិច្ចទៅលើការរៀបចំបួង់មុនពេលសាងសង់ ពេលសាងសង់ និងដំណើរការរបស់គំរោង។ ផែនការគ្រប់គ្រងបរិស្ថាន ផ្តល់នូវវិធានការកាត់បន្ថយសំរាប់ហេតុប៉ះពាល់បរិស្ថាននិមួយៗជាមួយនឹងភ្នាក់ងារទទួលខុសត្រូវ និងតំលៃប៉ាន់ស្មានសំរាប់ការចំណាយ។ កម្មវិធីត្រួតពិនិត្យ នឹងរួមបញ្ចូលទាំងកាលវេលាដែលត្រូវធ្វើជារឿយៗ ស្ថាប័ន និង ថវិកាផងដែរ។

## *៧.១ ការរៀបចំស្ថាប័ន*

ការអនុវត្តន៏ ផ.គ.ប សំរាប់គំរោងនឹងត្រូវអនុវត្តដោយម្ចាស់គំរោង/ក្រុមហ៊ុនវិនិយោគ ក្នុងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញ ដូចជា ក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT) ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ (MLMUPC) គណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេស (TSMC)[1] មន្ទីរបរិស្ថានខេត្ត មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់ក្រសួងបរិស្ថាន នាយកដ្ឋានត្រួតពិនិត្យការបំពុលរបស់ក្រសួងបរិស្ថាន រដ្ឋបាលជលផល រដ្ឋបាលព្រៃឈើ ខ័ណ្ឌរដ្ឋបាលជលផល ខ័ណ្ឌរដ្ឋបាលព្រៃឈើ អ្នកម៉ៅការសាងសង់ និងអាជ្ញាធរមូលដ្ឋាន/ប៉ូលីស។

ក្រសួងសាធារណការ និង ដឹកជញ្ជូន (MPWT) និងគណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេស (TSMC) ទទួលបន្ទុកវាយតំលៃនិងពិនិត្យតាមដានបច្ចេកទេសក្នុងការរចនាប្លង់ និងការសាងសង់ស្ពានកោះពស់ បណ្តាញផ្លូវថ្នល់ និងការសាងសង់ប្រព័ន្ធអាងសំអាតទឹកក្រខ្វក់។

ក្រុមហ៊ុនកោះពស់ មានការទទួលខុសត្រូវរួម ដើម្បីធានាឱ្យបាននូវរាល់សកម្មភាពសាងសង់ និងដំណើការនឹងមិនមានគ្រោះថ្នាក់ដល់ធនធានបរិស្ថាន និងធនធានសង្គម ហើយអនុវត្តយ៉ាងហ្មត់ចត់ទៅតាមបទដ្ឋានបរិស្ថានដែលមានចែងក្នុង ផ.គ.ប សំរាប់ការសាងសង់ និងប្រតិបត្តគំរោងទាំងមូល។ ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និង/ឬ ប្រចាំខែនៅក្នុង និងនៅជុំវិញការដ្ឋានគំរោងកំឡុងពេលសាងសង់ និងដំណាក់កាល

[1] TSMC ក្រោមអធិបតីភាពឯ.ឧ **តូច ចាន់កុសល** អនុរដ្ឋលេខាក្រសួងសាធារណៈការ និងដឹកជញ្ជូន ជាប្រធាន, ឯ.ឧ **លូ គីមឈុន** អគ្គនាយកអជ្ញាធរកំពង់ផែក្រុងព្រះសីហនុ និង ឯ.ឧ **ស៊ុយ សាន** នាយខុទ្ទកាល័យក្រសួងសាធារណៈការ និងដឹកជញ្ជូន ជាអនុប្រធាន។ សមាជិកគណៈកម្មការរួមមាន លោក **បុង ប៊ុនហួន** ជាទីប្រឹក្សា, លោក **ភី សុភាត់** អគ្គនាយករងកិច្ចការសាធារណៈ, លោក **យិត ប៊ុណ្ណា** នាយកមជ្ឈមណ្ឌលស្រាវជ្រាវកិច្ចការសាធារណៈ, លោក **ឈឹម ផល្លា** វិស្វករស្ពានថ្នល់, និង លោក **ណុប ហេង** ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះសីហនុ។



Draft

ប្រតិបត្តិ ចាំបាច់ត្រូវធ្វើដើម្បីឱ្យប្រាកដថា អ្នកម៉ៅការបានគោរពតាម ផ.គ.ប ។ ការងារនេះនឹងចាំបាច់ត្រូវបញ្ចូលជាលក្ខខណ្ឌនៅក្នុងឯកសារកិច្ចសន្យាសាងសង់ ។

អ្នកម៉ៅការនឹងទទួលខុសត្រូវសំរាប់ការអនុវត្តន៍ប្រចាំថ្ងៃនូវ ផ.គ.ប ក៏ដូចជាខ្លឹមសារមានចែងនៅក្នុងឯកសារនៃកិច្ចសន្យា ដើម្បីធានាបានថា សកម្មភាពសាងសង់ និងប្រតិបត្តិ គឺស្របតាមបច្ចេកទេស និងបទដ្ឋានបរិស្ថាន ។

ម្ចាស់គំរោង/អ្នកវិនិយោគគំរោង ត្រូវទទួលខុសត្រូវនូវរាល់ចំណាយទាំងអស់សំរាប់ការទូទាត់សងហេតុប៉ះពាល់ ថ្លៃកាត់បន្ថយបរិស្ថាន និងថ្លៃត្រួតពិនិត្យ អំឡុងពេលវិនិយោគគំរោងទាំងមូល ។ ទាមទារចាំបាច់ឱ្យមានកិច្ចសហប្រតិបត្តិការ និងសហការល្អជាមួយអ្នក/ស្ថាប័នជាប់ទាក់ទងនឹងគំរោង ដើម្បីធានាបានពីការអនុវត្តន៍ប្រកបដោយភាពរលូន និងភាពជោគជ័យនៅគ្រប់ដំណាក់កាលរបស់គំរោង ។

នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងនាយកដ្ឋានត្រួតពិនិត្យការបំពុលរបស់ក្រសួងបរិស្ថានត្រូវទទួលខុសត្រូវចំពោះការត្រួតពិនិត្យតាមដាន និងការអង្កេតនូវគ្រប់ហេតុប៉ះពាល់ដែលនឹងកើតមានឡើងនៅក្នុងតំបន់គំរោង ក៏ដូចជានៅក្នុងភូមិភាគនោះ ។ វាទាមទារអោយមានការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ឬការពិនិត្យនៅពេលបន្ទាន់ចាំបាច់ ។ ការគ្រប់គ្រងគុណភាពបរិស្ថាន និងការណែនាំពីទំរង់ការកាត់បន្ថយនឹងត្រូវផ្តល់ឱ្យទៅម្ចាស់គំរោង ក៏ដូចជាភ្នាក់ងារសាងសង់ និងប្រតិបត្តិការដើម្បីធ្វើឱ្យប្រាកដថា មិនមានហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរណាមួយកើតឡើងនៅក្នុងតំបន់គំរោងនោះទេ ។

រដ្ឋបាលជលផល រដ្ឋបាលព្រៃឈើ ខ័ណ្ឌរដ្ឋបាលជលផល ខ័ណ្ឌរដ្ឋបាលព្រៃឈើ និងភ្នាក់ងារអភិរក្សដទៃទៀតនៅក្នុងតំបន់គំរោង នឹងត្រូវទទួលខុសត្រូវចំពោះការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចលើហេតុប៉ះពាល់លើធនធានជលផល ធនធានព្រៃឈើ និងធនធានឆ្នេរ ។

អាជ្ញាធរមូលដ្ឋាន និងប៉ូលីសត្រូវទទួលខុសត្រូវសំរាប់ការសំរបសំរួល ការត្រួតពិនិត្យ និងការដោះស្រាយពីជំលោះផ្នែកសង្គមណាមួយដែលអាចកើតឡើងនៅក្នុងតំបន់គំរោង ។ ពួកគេក៏ត្រូវជួយដល់ម្ចាស់គំរោង ដើម្បីការពារមិនឱ្យមានការធ្វើចរាចរណ៍ថ្នាំញៀន និង សកម្មភាពខុសច្បាប់ផ្សេងៗទៀតនៅក្នុងតំបន់គំរោង ។

## ៧.២ វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

គំរោងនឹងប៉ះពាល់ដល់ធនធានសង្គម និងធនធានបរិស្ថានមួយចំនួននៅក្នុង និងនៅជុំវិញតំបន់គំរោងដោយសារសកម្មភាពគំរោងក្នុងដំណាក់កាលមុនសាងសង់ ពេលសាងសង់ និងពេលដំណើរការ ។ វិធានការកាត់បន្ថយដែលបានស្នើឡើង ដើម្បីបន្ធូរបន្ថយហេតុប៉ះពាល់អវិជ្ជមានដែលបានកំណត់សំរាប់រឿងរ៉ាវបរិស្ថាននិមួយៗនៅក្នុងដំណាក់កាលគំរោងខុសៗគ្នា គឺមានសង្ខេបនៅក្នុងតារាង ៧.២-១ ។ តំលៃប៉ាន់ស្មានលំអិតមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៨ ។

តារាង ៧.២.-១: វិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន

| រឿងរ៉ាវបរិស្ថាន | សកម្មភាព | គំរិតនៃហេតុប៉ះពាល់ | | | វិធានការកាត់បន្ថយ | ស្ថាប័នទទួលខុសត្រូវ | តំលៃប៉ាន់ស្មាន USD |
|---|---|---|---|---|---|---|---|
| | | តិច | មធ្យម | ខ្លាំង | | | |
| **ដំណាក់កាលមុនពេល សាងសង់** | | | | | | | |
| **ទីតាំងគំរោង និងការរចនាប្លង់** | ស្ពានស្នើសុំនឹងកាត់តាមឃ្លងធម្មជាតិនៅក្នុងតំបន់កោះពស់ ដែលជាកន្លែងផ្លូវនាវាចរណ៍សំរាប់កប៉ាល់ចេញចូលផែកំពង់សោម ។<br>សមាសធាតុជំនួយផ្សេងៗទៀតរបស់គំរោង និងជំរុំកម្មករ ដែលរៀបចំដាក់នៅជិតសំណង់ស្ពាន និងឆ្នេរហាវ៉ៃ នឹងធ្វើឱ្យមានការមិនសប្បាយ ចិត្តដល់អ្នកជិតខាង និងអ្នកទេសចរណ៍នៅឆ្នេរលំហែកាយ និងឆ្នេរហាវ៉ៃ ។ | | ✓ | | *ក្រុមហ៊ុនកោះពស់ (ខេមបូឌា) អ៊ិនវេសមេនគ្រុប អេលធីឌី នឹងអនុវត្តតាមគោលការណ៍បច្ចេកទេស ដែលបានអនុម័តដោយអន្តរក្រសួង និងរាជរដ្ឋាភិបាលកម្ពុជា:-*<br>- ***កំពស់ស្ពាន:*** *៣២.៥ ម៉ែត្រ គិតចាប់ពីផ្ទៃទឹកសមុទ្រជោរខ្ពស់បំផុត ។*<br>- ***គំលាតសសរស្ពាន:*** *២០០ម៉ែត្រ នៅត្រង់ចន្លោះកណ្តាលស្ពានសំរាប់ផ្លូវនាវា ។*<br>- ***សំភារតាំងភ្ជាប់ និងស្លាកសញ្ញាចរាចរ:*** *មានគំនូសចរាចរ បំពាក់ភ្លើងអគ្គិសនីតាមបណ្តោយស្ពានរួមទាំងខាងលើ និងខាងក្រោមស្ពានផងដែរ-បំពាក់បង្កាន់ដៃស្ពាន-បំពាក់ស្លាកសញ្ញាចរាចរណ៍ផ្សេងៗទៀតតាមលក្ខណៈបច្ចេកទេសកំណត់ ។*<br>- ***លក្ខណៈបច្ចេកទេសសាងសង់ស្ពាន:*** *គោរពតាមការណែនាំរបស់ក្រសួង-ស្ថាប័នជំនាញនៃរាជរដ្ឋាភិបាលកម្ពុជា និងអនុវត្តសុវត្ថិភាពការងារក្នុងពេលសាងសង់ ។*<br>*ក្រុមហ៊ុននឹងសហការល្អជាមួយគណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេសសាងសង់ស្ពានកោះពស់អន្តរក្រសួង អាជ្ញាធរមូលដ្ឋាន អ្នកដឹកនាំសហគមន៍ នៅពេលជ្រើសរើសទីតាំងការរៀបចំដាក់ សមាសធាតុទាំងអស់របស់គំរោង រួមទាំងជំរុំបុគ្គលិក-កម្មករនៅក្នុងបរិវេណគំរោង ។* | DE/PO, MPWT, TSMC | គ្មាន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ការសំអាតការដ្ឋានសាងសង់** | ការឆ្ការព្រៃ និងការឈូសឆាយដីសំរាប់ការដ្ឋានសាងសង់ ជំរុំកម្មករ និងសមាសធាតុបន្ទាប់បន្សំផ្សេងទៀតនឹងធ្វើឱ្យបាត់បង់ដើមឈើ និងកំរាលរុក្ខជាតិ ដែលបង្កឱ្យមានសំណឹកដី និងប៉ះពាល់ដល់គុណភាពទឹក ។ ការបំពុលខ្យល់ ធូលី សំលេង និងរំញ័រនឹងបង្កហេតុប៉ះពាល់ដល់ សហគមន៍ជិតខាង ។ | ✓ | | | - ការសំអាតទីតាំងនេះនឹងត្រូវធ្វើឡើងក្នុងដែនកំណត់សំរាប់តែធ្លាចាំបាច់ដែលបំរើឱ្យការសាងសង់ ។<br>- រៀបចំផែនការធ្វើការឈូសឆាយដីនៅរដូវប្រាំង ហើយវិធានការសំរាប់ការពារចំពោះដីនឹងត្រូវបានអនុវត្ត ដូចជា រៀបចំជាថ្នាក់ៗដូចកាំជណ្តើរ ការដាក់ក្រណាត់ដំពត់ចាប់យកកករដីនៅការដ្ឋាន ក្នុងទឹក និងមាត់ទឹក ។<br>- កំរិតកំណត់សំលេង និងរំញ័រចេញពីម៉ាស៊ីន គ្រឿងចក្រនៅពេលឈូសឆាយដី និងពេលកាប់ដើមឈើ នឹងត្រូវអនុវត្ត ។<br>- ប្រើប្រាស់គ្រឿងចក្រ និងយានយន្តដែលមានគុណភាពល្អ ។ គំរោងមានផែនការអនុវត្តការងារនៅ តែពេលថ្ងៃប៉ុណ្ណោះ ។ | PO | មាននៅក្នុងទុនវិនិយោគ |
| **ការអង្កេតភូគព្ភសាស្ត្រ** | ការខួងដី និងថ្មដើម្បីអង្កេតពីភូគព្ភសាស្ត្រនៅលើកោះពស់ ទីតាំងស្ពាន និងតំបន់អភិវឌ្ឍន៍ ឆ្នេរហាវ៉ៃអាចបង្កហេតុប៉ះពាល់ដល់គុណភាពទឹកតាមឆ្នេរនៅក្នុងតំបន់គំរោង ។ | ✓ | | | - ការការពារជាមូលដ្ឋានមួយចំនួនចំពោះ ភក់ ឬល្បាប់/ផេះ ចេញពីរណ្តៅខួងត្រូវបានផ្តល់ ដោយដាក់ក្រណាត់សំពត់ ឬសំណាញ់ប្លាស្ទិកពណ៌ខៀវចាប់យកកករដីនៅការដ្ឋានខួងក្នុងទឹក និងមាត់ទឹក ។<br>- កាកសំណល់ដី ឬផេះចេញពីរណ្តៅខួង និងទុកដាក់ក្នុងកន្លែងមានសុវត្ថិភាព ឬប្រើសំរាប់ចាក់បំពេញដីទីលានវាយកូនគោល ។<br>- ការកំណត់សំលេង និងរំញ័រចេញពីម៉ាស៊ីនខួងដី/ថ្ម នឹងត្រូវអនុវត្តន៍ស្របតាមបទដ្ឋានកំណត់សំរាប់សំលេង និងរំញ័ររបស់ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។ | PO/Contractor | មាននៅក្នុងទុនវិនិយោគ/កិច្ចសន្យា |
| **ដំណាក់កាលសាងសង់** | | | | | | | |
| **ចរាចរណ៍** | ភាពកកស្ទះចរាចរណ៍នឹងអាចកើតឡើង នៅលើផ្លូវក្នុងមូលដ្ឋាន ដែលបណ្តាលមកពីការដឹកជញ្ជូនសំភារៈសំណង់ចេញ និងចូលការដ្ឋានគំរោង ។ | ✓ | | | - ស្លាកសញ្ញាចរាចរណ៍ និងអ្នកសំរួលចរាចរណ៍ (ដូចជាប៉ូលីស) នឹងត្រូវផ្តល់ឱ្យបានគ្រប់គ្រាន់នៅតាមបណ្តោយផ្លូវក្នុងតំបន់គំរោង និងនៅក្នុងផ្លូវចេញចូលរបស់គំរោង ។<br>- អប់រំដល់អ្នកបើកបររបស់គំរោង គោរពតាមច្បាប់ចរាចរណ៍ផ្លូវគោករបស់ប្រទេសកម្ពុជា ។ | CE/PO | មាននៅក្នុងទុនវិនិយោគ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ចរាចរណ៍យ៉ាងមមាញឹកពីរថយន្តធំរបស់គំរោងក៏អាចបង្កការខូចខាតដល់ផ្លូវថ្នល់ផងដែរ ជាពិសេស កំណាត់ផ្លូវ២ធ្នូ នៅខាងមុខឆ្នេរហាវ៉ៃ។ | | | | - ក្រុមហ៊ុននឹងធ្វើការកែលំអ និងជួសជុលកំណាត់ផ្លូវ២ធ្នូ ដែលប្រើប្រាស់សំរាប់ជាផ្លូវចេញចូលរបស់ គំរោង។ | | |
| **សិទ្ធិប្រើប្រាស់ទឹក និងសិទ្ធិទូទៅ** | គំរោងមរកតនឹងប្រើប្រាស់ទឹកពីរដ្ឋាករ ទឹកក្រុងព្រះសីហនុ សំរាប់បំរើឱ្យការងារសាងសង់ទាំងអស់ ព្រមទាំងការប្រើប្រាស់ប្រចាំថ្ងៃ របស់បុគ្គលិក/កម្មករទៀតផង។<br>គំរោងនឹងប៉ះពាល់ដល់សកម្មភាពនេសាទរបស់អ្នកនេសាទមួយចំនួនដែលតែងតែធ្វើនេសាទនៅក្បែរតំបន់គំរោង ។ | ✓ | | | - គំរោងនឹងប្រើប្រាស់ទឹកពីប្រព័ន្ធទឹកស្អាតរបស់ក្រុង ដោយធ្វើកិច្ចសហការជាមុនជាមួយរដ្ឋាករទឹកក្រុងព្រះសីហនុ ដើម្បីឱ្យអង្គភាពនេះអាចពង្រីកសមត្ថភាពផ្គត់ផ្គង់បានសមស្របតាមតំរូវការ ប្រើប្រាស់ទូទាំងក្រុង។<br>- ក្រុមហ៊ុនធានាថា ការប្រើប្រាស់ទឹកពីរដ្ឋាករទឹកព្រះសីហនុមិនធ្វើឱ្យប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់អ្នកក្រុងទេ ដោយក្រុមហ៊ុនបានទទួលលិខិតឆ្លើយតបលេខ ៦៧២ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានបញ្ជាក់ថា អង្គភាពរដ្ឋាករទឹកក្រុងព្រះសីហនុមានលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតគ្រប់ គ្រាន់សំរាប់គំរោងមរកត។<br>- ក្រុមហ៊ុននឹងអនុញ្ញាតឱ្យអ្នកនេសាទធ្វើនេសាទជុំវិញកោះពស់ក្នុងចំងាយ ១០០ម៉ែត្រពីមាត់ទឹក លើកលែងតែកន្លែងសាងសង់ស្ពាន និងការដ្ឋានសាងសង់ស្ថានីយ៍ចតទូកទេសចរណ៍។ | CE/PO | មាននៅក្នុង ទុនវិនិយោគ |
| **សុខភាពសាធារណៈ** | គំរោងអាចមានហេតុប៉ះពាល់ទៅលើសុខភាពកម្មករ និងសហគមន៍ ដោយការបញ្ចេញខ្យល់កខ្វក់ សំលេងរំខាន និងរំញ័រចេញពីគ្រឿងចក្រសាងសង់ ឡាន ឬរថយន្តធំរបស់គំរោង។<br>ការគ្រប់គ្រងមិនត្រឹមត្រូវនូ | ✓ | | | - ក្រុមហ៊ុននឹងត្រូវអនុវត្តតាមបទដ្ឋានសុវត្ថិភាពការងារ ដោយផ្តល់ឧបករណ៍ និងបរិក្ខារគ្រប់គ្រាន់ (ស្បែកជើងកវែង ស្រោមដៃ មួកការពារ វ៉ែនតាការពារភ្នែក។ល។ ដើម្បីការពារគ្រោះថ្នាក់ ផ្សេងៗដល់បុគ្គលិក-កម្មករ គំរោង។<br>- អប់រំបុគ្គលិក/កម្មករគំរោងអំពីសុវត្ថិភាពការងារ និងការថែទាំសុខភាពអនាម័យឱ្យបានគ្រប់គ្រាន់។<br>- គំរោងនឹងផ្តល់ទឹកស្អាត និងសាងសង់ជំរំកម្មករដែលមានបំពាក់បង្គន់អនាម័យសំរាប់បុគ្គលិកកម្មករប្រើប្រាស់ និងស្នាក់នៅបានសមរម្យ។ | CE/PO | មាននៅក្នុង ទុនវិនិយោគ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | វសំណល់ដែលកើតពីសកម្មភាពសាងសង់ និងមនុស្សនៅការដ្ឋាន និងនៅជំរុំកម្មករ/បុគ្គលិកតំរោង ។<br>តំរោងអាចបង្កហេតុប៉ះពាល់ដល់សុខ ភាពប្រជាជនមូលដ្ឋានតាមរយៈការចំលងជំងឺមួយចំនួន ដូចជា អេដស៍ ផ្តាសាយបក្សី ជំងឺឆ្លងកាចសាហាវដទៃទៀត ការសេពថ្នាំញៀន និងជួញដូរគ្រឿងញៀន ។ | | | | - គ្រប់គ្រងសំណល់រឹងទាំងនៅក្នុងការដ្ឋានសាងសង់ និងជំរុំកម្មករឱ្យបានត្រឹមត្រូវ ។<br>- ការការពារ និងព្យាបាលនឹងត្រូវបានផ្តល់ឱ្យដោយម្ចាស់តំរោង ឧទាហរណ៍. សេវាថែទាំសុខភាព ថ្នាំពេទ្យ និងគ្រូពេទ្យ/វេជ្ជបណ្ឌិត ដើម្បីពិនិត្យ និងព្យាបាលបុគ្គលិក/កម្មករតំរោង ។<br>- សហប្រតិបត្តិការល្អជាមួយស្ថាប័នសុខភាពនៅក្រុងព្រះសីហនុ និងថ្នាក់ជាតិដើម្បីការពារជំងឺឆ្លង ណាមួយនៅក្នុង និងនៅជុំវិញតំបន់តំរោង ។<br>- ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការជាមួយប៉ូលីស និងអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់ការប្រើប្រាស់ ថ្នាំញៀន និងចរាចរណ៍ថ្នាំញៀននៅក្នុងតំបន់តំរោង ។ | | |
| **ផ្លូវនាវាចរណ៍** | តំរោងនឹងរំខានដល់ផ្លូវនាវាចរណ៍កាត់ តាមឃ្លងធម្មជាតិនៅតំបន់កោះពស់ អំឡុងពេលសាងសង់ស្ពានកោះពស់ ។ | ✓ | | | - ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយអាជ្ញាធរកំពង់ផែកំពង់សោម និងប្រើប្រាស់ផ្លូវវាងវៀង ជាបណ្តោះអាសន្នសំរាប់សកម្មភាពនាវាចរណ៍ក្នុងដំណាក់កាលសាងសង់ស្ពាន ។<br>- ជូនដំណឹងឱ្យបានគ្រប់គ្រាន់ដល់អ្នកនេសាទ ភ្នាក់ងារទេសចរណ៍ និងប្រជាជនមូលដ្ឋានឱ្យប្រើប្រាស់ ផ្លូវនាវាចរណ៍ផ្សេងទៀតសំរាប់បើកបរទូករបស់គេនៅឆ្ងាយពីការដ្ឋានសាងសង់ស្ពានដើម្បីជៀស វាងគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ ។<br>- មានផ្តល់ស្លាកសញ្ញាសុវត្ថិភាពនៅជុំវិញការដ្ឋានស្ពាន និងមានបណ្តែតពោងបង្ហាញទិសដៅសំរាប់ ការធ្វើនាវាចរណ៍វាងការដ្ឋានសាងសង់ទៀតផង ។ | CE/PO | មាននៅក្នុងទុនវិនិយោគ |
| **ប៉ានលេខា** | តំរោងនឹងផ្លាស់ប្តូរកំពស់ផ្ទៃដីធម្មជាតិនៅកន្លែងមួយចំនួនជាពិសេសនៅលើកោះពស់ ដោយសារការឈូសឆាយដី ការជីកកាយ | ✓ | | | - ការការពារបរិស្ថានលើការផ្លាស់ប្តូរប៉ានលេខានៅក្នុងតំបន់តំរោងជាមួយនឹងទិដ្ឋភាពបច្ចេកទេស និងសេដ្ឋកិច្ចសំរាប់ការសាងសង់ផ្លូវនឹងត្រូវអនុវត្ត ។<br>- តំរោងមានផែនការជៀសវាងការបំបែកយកផ្ទាំងថ្មច្រើនពេក ឬការជីកយកដីជ្រៅហួសហេតុ ហើយមានការរៀបចំជាថ្នាក់ៗចំពោះការដ្ឋានសាងសង់មួយចំនួន ដើម្បី | CE/PO | គ្មាន |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ដី ដើម្បីសាងសង់ផ្លូវ និងអាគារនៅលើកោះពស់ ។ | | | | កាត់បន្ថយការផ្លាស់ប្តូរវាំន លេខានៃដីកោះនេះ ។ | | |
| **សំណឹកដី** | សំណឹកដីអាចកើតឡើងនៅការដ្ឋានផ្នែកចុងទាំងសងខាងនៃស្ពាន ការដ្ឋានសាងសង់ផ្លូវ និងអាគារលើកោះ ដោយសារសណ្ឋានដី និងប្រភេទដីនៃតំបន់កោះពស់នេះ ។ | | ✓ | | - ការសំអាតរុក្ខជាតិក្នុងការដ្ឋានសាងសង់នានារបស់គំរោងមរកត នឹងត្រូវកំណត់ទំហំជាអប្បបរមា សំរាប់តែការសាងសង់ ។<br>- ការឈូសឆាយដីនៅក្នុងការដ្ឋានសាងសង់នឹងត្រូវធ្វើតែនៅរដូវប្រាំង ឬគ្មានភ្លៀង ។<br>- វិធានការ/ការទប់ស្កាត់សំណឹកដីសមស្របនឹងត្រូវអនុវត្ត ដូចជាការដាំដុះរុក្ខជាតិឡើងវិញភ្លាមៗ បន្ទាប់ពីបកស្រទាប់ដីលើ ជីកធ្វើជាថ្នាក់ៗដើម្បីបន្ថយជំរាលចោត ឬតម្រៀបថ្មនៅកន្លែងដែល មានដីងាយទទួលរងសំណឹក ។ | CE/PO | មាននៅក្នុងទុនវិនិយោគ |
| **ធនធានឆ្នេរ** | សកម្មភាព សាងសង់នៅតំបន់កោះពស់ នឹងបន្ថយនូវតំលៃធនធានមួយចំនួនអាស្រ័យការធ្វើឱ្យគ្រខ្វក់ដោយសារគំរោង ដូចជាភាពមិន សប្បាយចិត្តនៃការមើលឃើញហ្វូងមនុស្ស និង សំលេងអ៊ូអរកើតចេញពីកម្មករ និងគ្រឿងចក្រសាងសង់នៃការដ្ឋានសំណង់ ។<br>ការគ្រប់គ្រងសំណល់រឹងមិនបានត្រឹមត្រូវនៅកន្លែងសាងសង់ ការចោលកាកសំណល់លើដីទៅក្នុងទឹក ឬនៅលើឆ្នេរ ធ្វើឱ្យខូចធនធាន តាមឆ្នេរ ដូចជាធ្វើឱ្យគ្រខ្វក់ឆ្នេរតាមមាត់ច្រាំង និង | ✓ | | | - នឹងដាក់របងស័ង្កសីកំពស់២ម៉ែត្រយ៉ាងតិចនៅជុំវិញការដ្ឋានសំណង់ ជាពិសេសនៅការដ្ឋានស្ពាន និងការដ្ឋាននៅលើឆ្នេរហាវ៉ៃ ។<br>- គ្រឿងលំអផ្នែក (ផ្ទាំងរូបភាពស្អាតៗ) នឹងត្រូវបំពាក់លើរបងការដ្ឋានផងដែរ បើចាំបាច់ ។<br>- ការទប់ស្កាត់កករទឹក និងកំទេចកំណអោយបានល្អ ជាតំរូវការចាំបាច់នៅគ្រប់កន្លែងនៃការដ្ឋាន សាងសង់នៅក្នុងទឹក និងនៅឆ្នេរសមុទ្រ/មាត់ទឹក ។ ជាឧទាហរណ៍ គេអាចដាក់ក្រណាត់ស្កាត់កករដីនៅជុំវិញកន្លែងសាងសង់នៅក្នុងទឹក ហើយសាងសង់ស្រះរងកករនៅកន្លែងសាងសង់នៅក្បែរ ឆ្នេរសមុទ្រ ឬតាមមាត់ទឹក ។<br>- គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន ឬប្រេងរំអិលដែលចេញពីសកម្មភាពសាងសង់ឱ្យបានត្រឹមត្រូវ ដោយប្រមូលទុកដាក់ក្នុងធុង និងប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេងៗ ។<br>- ធ្វើការថែទាំ និងជួសជុលគ្រឿងចក្រដែលបំរើការឱ្យគំរោងមិនឱ្យលេចកំពប់ប្រេង និងខ្លាញ់ ទៅលើដី ឬក្នុងទឹក ។<br>- អប់រំដល់កម្មករមិនឱ្យចោលកាកសំណល់ចូលទៅក្នុងប្រភពទឹក ហើយផ្តល់មធ្យោ | PO/Contractor | មាននៅក្នុងទុនវិនិយោគ/កិច្ចសន្យា |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | កន្លែងទឹកភាក់ ។<br>ទឹកដែលមានកករ និង កំទេចកំណខ្ពស់ ដែលកើតពីសកម្មភាពសាងសង់ នឹងធ្វើឱ្យគ្រខ្វក់ និងបំផ្លាញដល់ច្រាំងសមុទ្រ និងគុណភាពទឹក ។ | | | | បាយគ្រប់គ្រាន់ដើម្បីគ្រប់គ្រងកាកសំណល់ រួមបញ្ចូលទាំងការសាងសង់បង្គន់អនាម័យនៅក្នុងទីកន្លែងសាងសង់ និង ជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករគំរោង ។ | | |
| ព្រៃឈើ និង សត្វព្រៃ | ការកាប់ព្រៃឈើប្រមាណជា ៤៦ហ.ត ឬ៤៧% នៃទំហំព្រៃឈើសរុបនៅលើកោះ ដើម្បីសាងសង់ផ្លូវ អាគារ និងហេដ្ឋារចនាសម្ព័ន្ធ ដទៃទៀត ។<br>ការកាប់ព្រៃឈើការទន្ទ្រានចូលក្នុងព្រៃ លើកោះពីសំណាក់កម្មករសំណង់ដើម្បីចាប់ សត្វព្រៃ អាចប៉ះពាល់ដល់សត្វព្រៃនៅលើកោះពស់ ។ | ✓ | | | - ការកាប់ព្រៃឈើនឹងត្រូវធ្វើឡើងក្នុងដែនកំណត់នៃតំរូវការទីកន្លែងសំរាប់សកម្មភាពសាងសង់ គំរោងប៉ុណ្ណោះ ។<br>- ដាំដើមឈើ ឬរុក្ខជាតិដទៃទៀតឡើងវិញនៅបន្ទាប់ពីបញ្ចប់សកម្មភាពសាងសង់ជាក់ស្តែងនៅតាម ការដ្ឋានទីមួយៗ ។<br>- ហាមឃាត់កម្មករសំណង់ដាច់ខាត ពីការទន្ទ្រានចូលព្រៃដើម្បីបរបាញ់សត្វ និងកាប់ព្រៃឈើ ។<br>- ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសហការល្អជាមួយខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ រដ្ឋបាលព្រៃឈើ និងក្រសួងកសិកម្មដើម្បីសុំការអនុញ្ញាតកាប់ដើមឈើលើកោះមួយចំនួនសំរាប់ការដ្ឋានសាងសង់ ។<br>- ក្រុមហ៊ុនកោះពស់នឹងអនុវត្តតាមកិច្ចសន្យាជួលកោះពស់ក្នុងក្រុងព្រះសីហនុរវាងក្រុមហ៊ុនកោះពស់ ជាមួយរាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៦ ដែលមានចែងក្នុងកថាខ័ណ្ឌទីបី ត្រង់ចំនុច ៣.៣ ថា " ក្នុងការអនុវត្តន៍គំរោង ភាគី(ខ) មានសិទ្ធិកាប់ឆ្ការព្រៃ ដើម្បីអភិវឌ្ឍន៍លើ ទីតាំងវិនិយោគតាមប្លង់មេ ។ ដើមឈើទាំងអស់នៅលើទីតាំងវិនិយោគដែលត្រូវកាប់សំរាប់គោលបំណងនៃសិទ្ធិប្រើប្រាស់ទីតាំងវិនិយោគដែលបានអនុញ្ញាត ហើយប្រសិនបើដើមឈើទាំងនោះមានតំលៃសេដ្ឋកិច្ចនោះ ភាគី(ខ) ត្រូវបង់ចំណូលជូនរដ្ឋស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន | CE/PO | មាននៅក្នុង ទុនវិនិយោគ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | ទើបមានសិទ្ធិប្រើប្រាស់ ឬលក់ឈើទាំងនោះដោយស្របច្បាប់ ។ ពុំនោះទេ ឈើដែលកាប់រួចហើយ ត្រូវប្រគល់ជូនរដ្ឋវិញ ។ ” | | |
| **ភាវរសក្នុងទឹក/មច្ឆា** | នៅដំណាក់កាលសាងសង់ គំរោងអាច ប៉ះពាល់ដល់ជីវិតសត្វក្នុងទឹកដូចជា មឹក បង្គា ត្រី ត្រីគុកែ និងផ្កាថ្ម ដែលរស់នៅក្នុងតំបន់កោះពស់ ។ ហេតុប៉ះពាល់ដល់ធនធានទាំងនោះបណ្តាលពីការប្រែប្រួលគុណភាពទឹក (ទឹកមានកករ/ភាពល្អក់ខ្ពស់ កាកសំណល់កំពប់ចូលទៅក្នុងទឹក សំលេង និងរំញ័រចេញពីសកម្មភាពសាងសង់) ។ ជូនកាលការនេសាទខុសច្បាប់ (បំផ្ទុះ ឬប្រើថ្នាំបំពុល) ពីសំណាក់កម្មករសំណង់ ក៏បណ្តាលឱ្យមានហេតុប៉ះពាល់ ឬបំផ្លាញភាវរសក្នុងទឹក និងធនធានមច្ឆា នៅក្នុងគំរោងផងដែរ ។ | | ✓ | | - ការទប់ស្កាត់កករដី និងកំទេចកំណឱ្យបានល្អគឺជាតំរូវការចាំបាច់នៅគ្រប់កន្លែងនៃការដ្ឋានសាងសង់នៅក្នុងទឹក និងនៅឆ្នេរសមុទ្រ/មាត់ទឹក ដោយដាក់ក្រណាត់ស្កាត់កករដីនៅជុំវិញកន្លែងសាងសង់នៅក្នុងទឹក ហើយសាងសង់ស្រះរងកករនៅកន្លែងសាងសង់នៅឆ្នេរសមុទ្រ ឬតាមមាត់ទឹក ។<br>- គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន ឬប្រេងរំអិលនានាឱ្យបានត្រឹមត្រូវ ដោយប្រមូលទុកដាក់ក្នុងធុង និងប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេងៗ ។<br>- ថែទាំ និងជួសជុលគ្រឿងចក្រ និងយានយន្តគំរោងមិនឱ្យលេចកំពប់ប្រេង/ខ្លាញ់លើដីឬក្នុងទឹក ។<br>- អប់រំដល់កម្មករមិនឱ្យចោលកាកសំណល់ចូលទៅក្នុងប្រភពទឹក ហើយផ្តល់មធ្យោបាយគ្រប់គ្រាន់ ដើម្បីគ្រប់គ្រងកាកសំណល់ រួមបញ្ចូលទាំងសាងសង់បង្គន់អនាម័យនៅក្នុងទីកន្លែងសាងសង់ និង ជំរំស្នាក់នៅ ។<br>- ហាមឃាត់ដាច់ខាតចំពោះកម្មករសំណង់មិនឱ្យធ្វើនេសាទខុសច្បាប់ ហើយក្រុមហ៊ុនធ្វើកិច្ចសហការជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ ដើម្បីធ្វើអធិការកិច្ច និងទប់ស្កាត់សកម្មភាពនេសាទខុសច្បាប់នៅក្នុងតំបន់គំរោង ។ | PO/Contractor | មាននៅក្នុងទុនវិនិយោគ/កិច្ចសន្យា |
| **ទេសភាព** | ក្នុងអំឡុងពេលសាងសង់ គំរោង នឹងមាន ហេតុប៉ះពាល់ដល់ទេសភាពនៅក្នុងតំបន់ ដោយសារភាពផ្លាស់ប្តូរបានលេខា ពីការ | ✓ | | | - ក្រុមហ៊ុននឹងរៀបចំផែនការឱ្យបានល្អសំរាប់ការកាប់សំអាតរុក្ខជាតិសំរាប់ការដ្ឋានសាងសង់ចាំបាច់ ឧទាហរណ៍ការដ្ឋានសាងសង់នៅលើកោះពស់នឹងត្រូវធ្វើជាប្លុកៗ គឺមិនបើកចំហការដ្ឋានសាងសង់ នៅពេលតែមួយរួមគ្នានោះទេ ។<br>- ការដាំដុះរុក្ខជាតិឡើងវិញនៅកន្លែងដែលបានបញ្ចប់ការងារសំណង់ស៊ីវិល ដើម្បីរក្សា | CE/PO | មាននៅក្នុងទុនវិនិយោគ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ឈូសឆាយដី កាយបើកចំហផ្ទៃដី កាប់សំអាតរុក្ខជាតិ និងការដាក់ឧបករណ៍ សំភារៈ គ្រឿងចក្រ ស្នេកស្លុះ ។ ការបុកសសរគ្រឹះ និងសកម្មភាពសាងសង់ដទៃទៀត នឹងបង្កឱ្យមានភាពមិនស្រស់ស្រាយនៅតំបន់កោះពស់ ។ | | | | តំបន់ទាំងមូល ឱ្យមានភាពបៃតងដូចស្ថានភាពដើម ។<br>- គ្រឿងតែងលំអ (ផ្ទាំងរូបភាពស្អាតៗ) នៅបរិវេណការដ្ឋានសាងសង់ឆ្នេរហាវ៉ៃ និងការដ្ឋានដទៃ ទៀត នឹងត្រូវបានផ្តល់ឱ្យក្នុងអំឡុងពេលសាងសង់ ។ | | |
| **ការបំពុលខ្យល់** | ការភាយចេញពីម៉ាស៊ីនសាងសង់រួមមាន ធូលី/ភាគល្អិតអណ្តែត ខ្យល់ក្រខ្វក់ ($NO_2$, $SO_2$, CO) និងផ្សែងចេញពីការបំផ្ទុះថ្មនៅ ការដ្ឋាន ម៉ាស៊ីនភ្លើង ម៉ាស៊ីនលាយស៊ីម៉ង់ត៍ សកម្មភាពដឹកជញ្ជូនសំភារៈសំណង់ឱ្យគំរោងនឹងធ្វើឱ្យប៉ះពាល់ដល់គុណភាពខ្យល់ក្នុងតំបន់ ។ | ✓ | | | - ក្រុមហ៊ុននឹងប្រើប្រាស់ថាមពលអគ្គិសនីពីបណ្តាញអគ្គិសនីកម្ពុជាសាខាក្រុងព្រះសីហនុ ជាប្រភពអគ្គិសនីចំបងសំរាប់គំរោង ហើយម៉ាស៊ីនភ្លើងរបស់គំរោងប្រើសំរាប់តែពេលភ្លើងរដ្ឋដាច់ប៉ុណ្ណោះ ។<br>- ក្រុមហ៊ុននឹងប្រើម៉ាស៊ីនសាងសង់ និងឡានដឹកឬរថយន្តធំៗរបស់គំរោងដែលមានគុណភាពល្អ និងមានផ្សែងតិច ។<br>- គ្របសំភារៈសាងសង់ (ស៊ីម៉ង់ត៍ ខ្សាច់ ។ល ។) នៅពេលដឹកជញ្ជូនចូលទៅការដ្ឋានសាងសង់ ។<br>- ស្រោចទឹក លើគំនរគ្រួស ឬខ្សាច់ នៅរដូវប្រាំង ។ ត្រូវដាក់ក្រណាត់សើមសំរាប់ចាប់ធូលីនៅ កន្លែងបញ្ចេញធូលី ពីម៉ាស៊ីនលាយស៊ីម៉ង់ត៍ ។ | PO/Contractor | មាននៅក្នុងទុនវិនិយោគ/កិច្ចសន្យា |
| **គុណភាពទឹក** | គុណភាពទឹកនៅការដ្ឋានស្ថានកោះពស់ ឆ្នេរហាវ៉ៃ និងនៅជុំវិញកោះពស់ នឹងត្រូវថមថយគុណភាព ដោយសារសកម្មភាពសាងសង់ ដូចជាការឈូសឆាយដី | ✓ | | | - វិធានការ/ការទប់ស្កាត់គករល្អក់ និងសំណើកដីត្រឹមត្រូវនឹងត្រូវផ្តល់ (ដាក់ក្រណាត់ព័ទ្ធជុំវិញកន្លែង សាងសង់នៅក្នុងទឹក ឬក្បែរមាត់ទឹក) ។<br>- ក្រុមហ៊ុននឹងអប់រំបុគ្គលិក/កម្មករមិនឱ្យបោះចោលសំរាម/កាកសំណល់ចូលទៅក្នុងប្រភពទឹក ហើយផ្តល់សំភារៈគ្រប់គ្រងកាកសំណល់រាប់ទាំងសាងសង់បង្គន់អនាម័យឱ្យបានគ្រប់ | PO/Contractor | មាននៅក្នុងទុនវិនិយោគ/កិច្ចសន្យា |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ការខូង ការបុកសសរ ការសង់គ្រឹះស្ថាន ការចោលកាកសំណល់ ការកំពប់ឥន្ធនៈ និងប្រេងរំអិលពីម៉ាស៊ីន គ្រឿងចក្រសាងសង់ចូលទៅលើ ឆ្នេរសមុទ្រ/ ក្នុងទឹកសមុទ្រ ឬនៅតាមកន្លែងទំនេរក្បែរនោះ ។<br>ជួនកាលការបង្ហូរទឹកក្រខ្វក់ដ៏ច្រើនពី សកម្មភាព សាងសង់ និងជំរុំកម្មករចូលទៅក្នុងប្រភព ទឹក និងដីទំនេរអាចកើតមានឡើងផងដែរ ។ | | | | គ្រាន់នៅការ ដ្ឋានសំណង់ និងនៅជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករ ។<br>- គ្រប់គ្រងសំណល់ប្រេងម៉ាស៊ីន និងប្រេងរំអិលឱ្យបានត្រឹមត្រូវដោយប្រមូលទុកដាក់ក្នុងធុង និង ប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកយកទៅប្រើក្នុងបំណងផ្សេងៗ ។<br>- ថែទាំ និងជួសជុលគ្រឿងចក្រគំរោងមិនឱ្យលេចកំពប់ប្រេង និងខ្ចាញ់លើដី ឬក្នុងទឹក ។ | | |
| | | | | | - ការត្រួតពិនិត្យគុណភាពទឹកនៅជុំវិញការដ្ឋានគំរោង នឹងត្រូវអនុវត្តឱ្យបានទៀងទាត់ ដើម្បីធានាថា គុណភាពរបស់ទឹកនៅពេលសាងសង់មិនមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់ជីវិតសត្វ និងរុក្ខជាតិក្នុងទឹក និងមនុស្ស ។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹកគឺ TSS, DO, BOD5, Total N, Total P, Cd, Hg, and Pb ។ | PO | ២.០៤០/ឆ្នាំ (សរុប៥ឆ្នាំ គឺ ១០.២០០) |
| **កាកសំណល់** | សំណល់រឹងដូចជា កាកសំណល់នៃសំភារៈសំណង់ សំណល់ផ្ទះបាយ និងសំណល់ចេញពីមនុស្ស អាចកើតមាននៅការដ្ឋានសាងសង់ និង ជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករគំរោង ។<br>ការគ្រប់គ្រងកាកសំណល់ក្នុងការដ្ឋានសាងសង់ និងក្នុងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករ មិនបានល្អ នឹងបង្ក ឱ្យមានបញ្ហាជា | ✓ | | | - ក្រុមហ៊ុននឹងអប់រំកម្មករមិនឱ្យបោះចោលកាកសំណល់ទៅក្នុងខ្សែទឹក និងផ្តល់ឱ្យនូវសេវាកម្ម គ្រប់គ្រងសំរាមរួមទាំងបង្គន់អនាម័យក្នុងទីតាំងការដ្ឋានសាងសង់ និងក្នុងជំរុំបុគ្គលិក/កម្មករ ។ ជាក់ស្តែង ក្រុមហ៊ុនកោះពស់មានកិច្ចសន្យាជាមួយក្រុមហ៊ុន CINTRI សាខាក្រុងព្រះសីហនុ ដើម្បីប្រមូលសំរាមការិយាល័យ និងសំរាមផ្ទះបាយយកទៅបោះចោល ។<br>- ក្រុមហ៊ុននឹងសាងសង់ស្រះរងកករ ដែលមានតួនាទីសំអាតបឋមនៃទឹកដែលប្រើប្រាស់ចេញពីការ ដ្ឋានសាងសង់ និងជំរុំស្នាក់នៅរបស់បុគ្គលិក/កម្មករ ។ សំភារៈសំលាប់មេរោគ ដូចជា ម្សៅកំបោររស់ និងក្ល័រនឹងត្រូវបានប្រើដើម្បីសំអាតទឹកក្នុងស្រះរងកករ ក្នុងករណីបើចាំបាច់ ។<br>- គ្រប់គ្រងសំណល់សំភារៈសំណង់ឱ្យបានត្រឹមត្រូវ ដូចជា ឈើ ដែក ក្រដាស និង | CE/PO | មាននៅក្នុងទុនវិនិយោគ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ច្រើន ដូចជា ធ្វើឱ្យខូចសោភ័ណ្ឌភាព បំពុលគុណភាពដី គុណភាពខ្យល់ និងគុណភាពទឹក បង្កើតជំរក និងសត្វចង្រៃចំលងរោគ ដូចជា មូស រុយ ហើយចុងក្រោយគឺប៉ះពាល់ដល់សុខភាពសត្វ ក្នុងទឹក សត្វពាហនៈ និងសុខភាពមនុស្ស ។ | | | | ស្បោងប្លាស្ទិក ព្រមទាំងសំណល់ប្រេង និងប្រេងរំអិលចេញពីគ្រឿងចក្រសាងសង់ ដោយប្រមូលទុកក្នុងធុងដើម្បី ប្រើប្រាស់ឡើងវិញ ឬលក់ឱ្យអ្នកប្រើប្រាស់ផ្សេងទៀត ។ | | |
| **សំលេង និងរំញ័រ** | សំលេង និងរំញ័រដែលកើតចេញពីគ្រឿង ចក្រសាងសង់ ជាពិសេស ការបុកសសរគ្រឹះ រថយន្តធំៗ/យានយន្ត ប្រើសំរាប់ដឹកជញ្ជូន សំភារៈសំណង់នឹងកើតមានឡើងនៅក្នុង និងនៅជុំវិញការដ្ឋានសាងសង់ ។ សំលេង និងរំញ័រនៅ ការដ្ឋានសាងសង់ស្ពានកោះពស់ និងឆ្នេរហាវ៉ៃ គឺចាត់ជាប្រភពបំពុលដល់សហគមន៍នៅទីនេះ ។ | ✓ | | | - ក្រុមហ៊ុនកោះពស់ នឹងប្រើប្រាស់គ្រឿងចក្រ និងរថយន្តធំៗ/យានយន្តគំរោងទាំងអស់ដែលមាន គុណភាពល្អ បញ្ចេញសំលេង និងរំញ័រតិច ។<br>- ក្រុមហ៊ុននឹងផ្តល់ឧបករណ៍ និងសំភារៈ ដូចជា កាស់ពាក់នៅត្រចៀកការពារសំលេង ជូនដល់បុគ្គលិក កម្មករគំរោងនៅការដ្ឋានធ្វើការដែលមានសំលេងខ្លាំង ។<br>- រាល់សកម្មភាពសាងសង់ទាំងអស់របស់គំរោងមរកត នឹងត្រូវអនុវត្តនៅក្នុងរយៈពេលម៉ោងធ្វើការពេលថ្ងៃ (៧:៣០-១១:៣០ និង ១៣:៣០-១៧:៣០) និងគោរពតាមកំរិតកំណត់សំលេងក្នុង តំបន់សាធារណៈ ដូចមានចែងក្នុងឧបសម្ព័ន្ធទី៦នៃ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និង ការរំខានដោយសំលេង ។ | CE/PO | មាននៅក្នុងទុនវិនិយោគ |
| **ដំណាក់កាលប្រតិបត្តិ** | | | | | | | |
| **ចរាចរណ៍** | ការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរា ចរណ៍អាចកើតមានឡើង នៅលើផ្លូវដែលពាក់ព័ន្ធទៅ | ✓ | | | - ក្រុមហ៊ុននឹងបំពាក់ភ្លើងចរាចរណ៍ ស្លាកសញ្ញាចរាចរណ៍ និងភ្លើងបំភ្លឺនៅតាមបណ្តោយស្ពានទាំងសងខាង ខាងក្រោមស្ពាន ដូចមានចែងក្នុងកិច្ចសន្យាបន្ថែមរវាងក្រុមហ៊ុនកោះពស់ ជាមួយរាជរដ្ឋា ភិបាលកម្ពុជា ។ | OE/PO | មាននៅក្នុងទុនវិនិយោគ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | នឹងកិច្ចដំណើរការ តំរោងមរកត ជាពិសេស ផ្លូវពីរថ្ន និងស្ពានកោះពស់ ដោយការកើនឡើង នូវរថយន្ត ឡានធំ ម៉ូតូ និងទោចក្រយាន ដែលចរាចរណ៍លើផ្លូវក្នុងតំបន់តំរោង។ ជូនកាល គ្រោះថ្នាក់ចរាចរណ៍អាចកើតឡើងនៅលើស្ពានផងដែរ ដោយសារការធ្វេសប្រហែសរបស់ អ្នកបើកបរ ឬអ្នកប្រើប្រាស់ផ្លូវ/ស្ពាន។ | | | | - ក្រុមហ៊ុនកោះពស់នឹងធ្វើសហប្រតិបត្តិការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ ដើម្បីបំពាក់ភ្លើងបំភ្លឺ និងស្លាកសញ្ញាចរាចរណ៍លើផ្លូវពីរថ្ន។<br>- ក្រុមហ៊ុនកោះពស់នឹងធ្វើសហប្រតិបត្តិការជាមួយភ្នាក់ងារប៉ូលីសក្នុងក្រុងព្រះសីហនុ ដើម្បីផ្តល់ប៉ូលីសចរាចរណ៍ដើម្បីប្រចាំការលើច្រកចូលស្ពាន និងកន្លែងប្រសព្វគ្នានៃផ្លូវសំខាន់ៗនៅក្នុងតំបន់ តំរោង។ | | |
| **សិទ្ធិប្រើប្រាស់ទឹក និងសិទ្ធិទូទៅ** | តំរោងនឹងមានហេតុប៉ះពាល់ដល់គ្រួសារ អ្នកនេសាទមួយចំនួន បើសិនតំរោងនឹងហាមឃាត់សកម្មភាពនេសាទបែបគ្រួសារនៅទីនេះ។ | ✓ | | | - ក្រុមហ៊ុននឹងអនុញ្ញាតឱ្យអ្នកនេសាទធ្វើសកម្មភាពនេសាទជុំវិញកោះពស់ក្នុងចំងាយ ១០០ម៉ែត្រ ពីមាត់ទឹក ដើម្បីថែរក្សាភាពស្ងប់ស្ងាត់ និងសុវត្ថិភាពដល់ប្រជាជាន និងភ្ញៀវដែលរស់នៅលើកោះ។<br>- ក្រុមហ៊ុននឹងផ្តល់អាទិភាពជ្រើសរើសគ្រួសារអ្នកនេសាទដែលនឹងរងផលប៉ះពាល់ឱ្យចូលធ្វើការជា បុគ្គលិក/កម្មកររបស់តំរោងទេ អំឡុងពេលប្រតិបត្តិតំរោង។ | PO | គ្មាន |
| **សុខភាពសាធារណៈ** | ការគ្រប់គ្រងសំណល់រឹងមិនបានត្រឹមត្រូវ នៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃនឹងបង្កឱ្យមានក្លិនស្អុយ គ្រុនក្តៅ និងគ្រុនក្តៅចាញ់ ព្រមទាំងបង្កើត ជំរកបាក់តេរី និងភ្នាក់ងារចំលងជំងឺ ដែលនាំឱ្យប៉ះពាល់ដល់សុខភាពមនុស្ស។ | ✓ | | | - ក្រុមហ៊ុននឹងផ្តល់ឱ្យគ្រប់គ្រាន់នូវគ្រឿងសំភារៈគ្រប់គ្រងសំណល់រឹងដូចជា ធុងដាក់សំរាម និងកន្លែងដាក់សំរាមតាមការរចនាប្លង់ទាន់សម័យទំនើបសំរាប់តំបន់រមណីយដ្ឋាន (ធុងសំរាមមានបីប្រភេទ ដូចជា (១) ធុងសំរាមក្រដាស់/ប្លាស្ទិក/កំទេចដែក/កែវ (២) ធុងសំរាមសំណល់អាហារនិងបន្លែ និង (៣) ធុងសំរាមគ្រោះថ្នាក់(ថ្មពិល អាគុយ សំណល់ថ្នាំពេទ្យ និងសារធាតុពុលនានា។ល។)<br>- ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនផ្តល់សេវាកម្មប្រមូលសំរាម (ដូចជា CINTRI) ដើម្បីប្រមូល ដឹកជញ្ជូន និងយកទៅបោះចោលរាល់សំណល់រឹង | OE/PO | មាននៅក្នុងទុនវិនិយោគ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ការគ្រប់គ្រងទឹកក្រខ្វក់មិនបានល្អ ឬភាពមិនដំណើរការល្អនៃអាងធ្វើប្រព្រឹត្តកម្មសំអាតទឹកស្អុយនៅលើកោះពស់ ក៏ដូចជានៅឆ្នេរហាវ៉ៃ នឹងបំពុលគុណភាពទឹកនៅជុំវិញ កន្លែងដែលបង្ហូរចេញ បឹងប៉ះពាល់ដល់សុខភាពភ្ញៀវ ឬអ្នកមកលេងទឹកក្នុងតំបន់នោះ ។ | | | | ទាំងអស់ដែលកើតចេញពីកិច្ចដំណើរ ការតំរោងមរកតទាំងមូល ។<br>- ក្រុមហ៊ុនធ្វើការត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថាកិច្ចដំណើរការនៃអាងធ្វើប្រព្រឹត្តិកម្មទាំងអស់របស់តំរោងមានដំណើរការល្អ ដែលធានាបានទូវតំលៃនៃគីរីតប៉ារ៉ាម៉ែត្របង្ហូរចេញស្របតាមបទដ្ឋានបង្ហូរចេញទៅតំបន់ទឹកសាធារណៈ ដែលកំណត់ដោយក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ។<br>- ក្រុមហ៊ុនមរកតមានសាងសង់មន្ទីរពហុព្យាបាល ឬមណ្ឌលសុខភាពនៅលើកោះពស់ និងមានផ្តល់ សេវាកម្មថែទាំសុខភាពចំពោះភ្ញៀវទេសចរណ៍ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តព្រះសីហនុផងដែរ ។<br>- ក្រុមហ៊ុនកោះពស់នឹងធ្វើសហប្រតិបត្តិការល្អជាមួយភ្នាក់ងារថែទាំសុខភាពថ្នាក់មូលដ្ឋានថ្នាក់ជាតិ និងថ្នាក់តំបន់ ឬថ្នាក់អន្តរជាតិដើម្បីដោះស្រាយរាល់បញ្ហាសុខភាពនៅក្នុងតំបន់តំរោង ។ | | |
| **ហានិយភ័យ** | ក្នុងពេលស្ពានដំណើរការ ស្ពាននេះអាច ជាកន្លែងគោលដៅសំរាប់មនុស្សមួយចំនួនធ្វើអត្តឃាត (អ្នកមោហាំង ឬអ្នកខូចចិត្ត ទៅលោតទឹក សម្លាប់ខ្លួន) ដូចធ្លាប់កើតមានឡើងជាធម្មតានៅស្ពានធំៗក្នុងប្រទេសកម្ពុជា ។<br>ជួនកាល ការរុញច្រានគ្នាដោយចេតនា ឬដោយអចេតនា និងការប្រច្រៀតគ្នាហួសហេតុនៅលើស្ពាន ក៏អាចបង្កជាគ្រោះ | ✓ | | | - ក្រុមហ៊ុននឹងមានដាក់ឆ្មាំស្ពាន និងប៉ូលីសឱ្យបានគ្រប់គ្រាន់នៅលើស្ពាន ព្រមទាំងរៀបចំឱ្យមានបីវេននៃឆ្មាំស្ពាន ដើម្បីធានាសុវត្ថិភាព ២៤ ម៉ោង លើ២៤ ម៉ោង ។<br>- ក្រុមហ៊ុននឹងសហការជាមួយប៉ូលីសក្នុងក្រុងព្រះសីហនុ និងភ្នាក់ងារដទៃទៀត ដើម្បីទប់ស្កាត់ និងដោះស្រាយចំពោះបញ្ហាដែលអាចកើតឡើងដូចមានរៀបរាប់ខាងលើ ។ | OE/PO | មាននៅក្នុងទុនវិនិយោគ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ថ្នាក់ដល់ជីវិត ានដែរ ។ | | | | | | |
| **ព្រៃឈើ និងសត្វព្រៃ** | គំរោងនឹងប៉ះពាល់ដល់សត្វព្រៃ ជាពិសេស ពពួកបក្សីនៅតំបន់កោះពស់ ដោយសារនៅពេលដំណើរការគំរោង និងមានមនុស្សច្រើនកុះករនៅលើកោះ ។ ជាងនេះទៀតនោះ ព្រៃឈើចំនួន ៤៦ហ.ត នៅលើកោះត្រូវបានបាត់បង់ក្នុងពេល សាងសង់គំរោង ដូចនេះសត្វព្រៃបានបាត់បង់ជំរករបស់វា ។ | ✓ | | | - *ការដាំឈើឡើងវិញនៅកន្លែងដីវាលចាំបាច់មួយចំនួនលើកោះពស់ ដែលអាចរក្សាបានជាជំរក បក្សីព្រៃ និងជំរកសត្វព្រៃដទៃទៀត ។ ធ្វើបានដូច្នេះអាចអភិរក្សនូវប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ នេះបានមួយចំនួន ។* | OE/PO | មាននៅក្នុងទុនវិនិយោគ |
| | គំរោងបានធ្វើឱ្យថយសមត្ថភាពស្រូប ជាតិឧស្ម័នកាបូនឌីអុកស៊ីតប្រមាណជា ២៤.១១៩ តោន/ឆ្នាំ ហើយបាត់បង់កំនើនមាឌឈើ ៤០ តោន/ឆ្នាំ ។ | | | | - *ក្រុមហ៊ុននឹងចូលរួមវិភាគទានក្នុងកម្មវិធីអភិរក្ស និងការដាំព្រៃឈើឡើងវិញនៅក្នុងខេត្តព្រះសីហនុ ឧទាហរណ៍ក្រុមហ៊ុននឹងចូលរួមវិភាគទានក្នុងទិវាដាំដើមឈើជាដើម ។ល ។* | PO | ជាថវិការដោយស្ម័គ្រចិត្តរបស់ម្ចាស់គំរោង |
| **ភាពវសក្នុងទឹក/មច្ឆា** | ហេតុប៉ះពាល់លើភាវរសក្នុងទឹក/មច្ឆាអាចនឹងកើតឡើង ដោយសារការបង្ហូរទឹកក្រខ្វក់ ដែលគ្មានការសំអាតចូលក្នុងប្រភពទឹក ការចោលសំណល់រឹងនៅលើឆ្នេរ ឬតាមមាត់ទឹក ។ | | ✓ | | - *គំរោងមរកតមានផែនការទប់ស្កាត់ និងធ្វើឱ្យប្រសើរឡើងនូវធនធានធម្មជាតិសំរាប់ការអភិវឌ្ឍផ្នែកទេសចរណ៍ ដូចនេះសកម្មភាពនេសាទ និងការប្រមូលវារីសត្វនឹងត្រូវមានកំណត់ ។*<br>- *ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ និងអនុញ្ញាតឱ្យអ្នក នេសាទធ្វើសកម្មភាពនេសាទនៅតំបន់កោះពស់ក្នុងចំងាយដែនកំណត់ពីមាត់ច្រាំង (យ៉ាងតិច ១០០ ម៉ែត្រ ពីច្រាំងកោះពស់) ។* | OE/PO | មាននៅក្នុងទុនវិនិយោគ |



Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | គំរោងនឹងមានហេតុប៉ះពាល់ តិច តួចទៅមធ្យម លើវាំរីសត្វ/ រាំរុក្ខជាតិ ជាមួយនឹងការបណ្តុំជាតិពុលជាបន្តបន្ទាប់ហូរចូលទៅក្នុងទឹក ។ ភាពងាយស្រួលក្នុងការចេញចូលបណ្តាលមកពីកិច្ចដំណើរការស្ថានអាចទាក់ទាញដល់អ្នកនេសាទ ឬភ្ញៀវទេសចរណ៍ចូលមកនិងធ្វើ នេសាទនៅតាមក្បែរច្រាំងកោះពស់ ។ | | | | - គ្រប់គ្រងឱ្យបានល្អចំពោះកាកសំណល់ដែលកើតចេញពីការប្រតិបត្តិគំរោង ។ ត្រួតពិនិត្យយ៉ាងខ្ជាប់ ខ្ជួនទូវអាងធ្វើប្រព្រឹត្តិកម្មទឹកស្អុយឱ្យមានដំណើរការល្អ ហើយតំលៃនៃចាំរាំមែត្របង្ហូរចេញគោរពតាមបទដ្ឋាននៃការបង្ហូរចូលតំបន់ទឹកធម្មជាតិដែលកំណត់ដោយក្រសួងបរិស្ថាន ។ | | |
| | | | | | - ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការល្អជាមួយខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ ដើម្បីត្រួតពិនិត្យ តាមដានរាំរីសត្វ/ត្រី និងរាំរីរុក្ខជាតិក្នុងតំបន់កោះពស់ទាំងមូលអំឡុងពេលដំណើរការគំរោង ។ នឹងមានផែនការធ្វើអង្កេតលើត្រី និងផ្កាថ្មនៅជុំវិញកោះពស់ (១០០ម ពីមាត់ច្រាំង) ជារៀងរាល់ពីរឆ្នាំម្តងពេញរយៈពេលប្រតិបត្តិការគំរោង ដើម្បីពិនិត្យមើលធនធានធម្មជាតិនេះ និងរកដំណោះស្រាយធ្វើយ៉ាងណារក្សានិរន្តភាពវាឱ្យបាន ។ | PO | ១៥.០០០/២ឆ្នាំ (សរុប ៦៧៥.០០០) |
| **ដីប្រើប្រាស់** | ការផ្លាស់ប្តូរនៃដីប្រើប្រាស់លើកោះពស់ គឺការថយចុះនូវព្រៃឈើក្នុងតំបន់ឆ្នេរ ដោយសារការអភិវឌ្ឍដី និងសកម្មភាពអភិវឌ្ឍន៍ផ្សេងទៀត នៅលើកោះ ហើយមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ីនៅលើកោះ និងអាចបង្កផលអាក្រក់ដល់ផៃព្រះសីហនុ ដោយសារខ្យល់បោកបក់ខ្លាំង និងរលកធំៗ ។ | ✓ | | | - ក្រុមហ៊ុននឹងរៀបចំផែនការអភិវឌ្ឍឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងបទដ្ឋានក្នុងន័យការអភិវឌ្ឍដែលមានលក្ខណៈសេដ្ឋកិច្ចផង និងការពារបានបរិស្ថានផង ។<br>- បញ្ចៀសរាល់ការបំផ្លិច បំផ្លាញដល់ធនធានបរិស្ថានធ្ងន់ធ្ងរ ជាពិសេសប្រព័ន្ធអេកូឡូស៊ីតំបន់កោះពស់ និង បញ្ចៀសរាល់ទំនាស់សង្គមធ្ងន់ធ្ងរក្នុងតំបន់គំរោង ។<br>- ក្រុមហ៊ុននឹងធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជំនាញនានាក្នុងខេត្តព្រះសីហនុ ក៏ដូចក្រសួងពាក់ព័ន្ធ ដើម្បីដោះស្រាយរាល់ទំនាស់នានាដែលទាក់ទងនឹងការអភិវឌ្ឍគំរោងនេះ ។ | PO | មាននៅក្នុងទុនវិនិយោគ |
| **ការបំពុលខ្យល់** | ការកើនឡើងនូវរថយន្តធុនធ្ងន់ និងរថយន្តដឹកផ្សេងៗនៅ | ✓ | | | - ការពារព្រៃឈើឱ្យបានល្អ (ដើមឈើ និងរុក្ខជាតិនានា) នៅលើកោះ និងនៅដីគោកនៅក្នុងតំបន់ កោះពស់ទាំងមូល ហើយការដាំដើមឈើនៅកន្លែងទំនេរ ឬនៅតាម | PO | មាននៅក្នុងទុនវិនិយោគ |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| | តំបន់កោះពស់ ក៏ដូចជា នៅក្នុងក្រុងព្រះសីហនុ និងបញ្ចេញផ្សែងក្រខ្វក់ មួយចំនួនចូលទៅក្នុងបរិយាកាសនៅក្នុងតំបន់។ ការបំភាយពីរថយន្តតូចធំ និងទោចក្រយានយន្ត ទាំងនោះ រួមមាន $NO_2$, $SO_2$, CO, និង TSP | | | | បណ្តោយផ្លូវក៏អាចជួយ រក្សាឱ្យមានខ្យល់អាកាសបរិសុទ្ធផងដែរ។ | | |
| **ការបំពុលទឹក** | ការបោះចោលសំរាមចូលក្នុងទឹកសមុទ្រ ឬនៅលើឆ្នេរកោះពស់ និងឆ្នេរហាវ៉ៃនឹងបំពុលគុណភាពទឹកនៃតំបន់ឆ្នេរសមុទ្រនេះ។ ជួនកាល ការបង្ហូរទឹកក្រខ្វក់មិនបានសំអាតចេញពីសហ គមន៍ ឬសកម្មភាពដំណើរការគំរោងចូលក្នុង ប្រភពទឹកអាចកើតមានឡើង។ | ✓ | | | - គ្រប់គ្រងឱ្យបានល្អចំពោះកាកសំណល់គំរោង ដែលកើតចេញពី លំនៅដ្ឋាន សណ្ឋាគារ អាគារ ការិយាល័យ តំបន់ពាណិជ្ជកម្ម និងតំបន់សាធារណៈនៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃ។ ជាឧទាហរណ៍សំណល់រឹង គឺមានការគ្រប់គ្រងយ៉ាងល្អដោយមានប្រព័ន្ធប្រមូលយកតាមការទាមទារ នៃបរិស្ថានស្អាតសមជាទីស្ថានទេស ហើយទឹកក្រខ្វក់គឺមានតភ្ជាប់យ៉ាងល្អត្រឹមត្រូវ និងធ្វើការ សំអាតដោយអាងធ្វើប្រព្រឹត្តកម្មមុននឹងបង្ហូរចេញចូលទៅក្នុងសមុទ្រ។<br>- ក្រុមហ៊ុននឹងថែទាំ និងត្រួតពិនិត្យយ៉ាងខ្ជាប់ខ្ជួននូវអាងធ្វើប្រព្រឹត្តកម្មទឹកស្អុយឱ្យមានដំណើរការល្អ ហើយតំលៃនៃប៉ារ៉ាម៉ែត្របង្ហូរចេញគោរពតាមបទដ្ឋាននៃការបង្ហូរចូលតំបន់ទឹកធម្មជាតិដែលបាន កំណត់ដោយក្រសួងបរិស្ថាន។ | | |
| | ការមិនដំណើរការល្អនៃអាងធ្វើប្រព្រឹត្តិ កម្មសំអាតទឹកក្រខ្វក់នៅ លើកោះពស់ និងនៅឆ្នេរហាវ៉ៃអំឡុងពេលប្រតិបត្តិគំរោងនឹងបំពុល គុណភាពទឹកសមុទ្រក្នុងតំបន់នេះ។ | | | | - ត្រួតពិនិត្យគុណភាពទឹកនៅជុំវិញទីតាំងគំរោង នឹងត្រូវអនុវត្តឱ្យបានទៀងទាត់ ដើម្បីធានាថា គុណភាពរបស់ទឹកនៅពេលប្រតិបត្តិគំរោងមិនមានផលប៉ះពាល់ធ្ងន់ធ្ងរ ដល់ជីវិតសត្វ និងរុក្ខជាតិ ក្នុងទឹក និងមនុស្ស។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹកគឺ TSS, DO, $BOD_5$, Total N, Total P, Cd, Hg, និង Pb. | PO | ១.០២០/ឆ្នាំ (សរុប ៥១.៨០០) |

Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| **កាកសំណល់** | ការចោលសំណល់រឹង/សំរាមលើផ្ទៃដី លើផ្លូវមាត់ទឹក និងក្នុងផ្ទៃទឹក ពីសំណាក់ភ្ញៀវទេសចរណ៍ ឬសហគមន៍រស់នៅលើកោះពស់ អំឡុងពេលប្រតិបត្តិគំរោងអាចនឹងកើតមានឡើង បើសិនប្រព័ន្ធគ្រប់គ្រងសំណល់រឹងមិនផ្តល់ឱ្យ បានគ្រប់គ្រាន់ និងមិនដំណើរការល្អ។ | ✓ | | | - *កាកសំណល់រឹងដែលកើតចេញពី លំនៅដ្ឋាន សណ្ឋាគារ អាគារ ការិយាល័យ តំបន់ពាណិជ្ជកម្ម និងតំបន់សាធារណៈនៅលើកោះពស់ និងនៅផ្លូវហាវ៉ៃនឹងត្រូវបានប្រមូលទុកដាក់ និងយកទៅបោះចោលតាមការទាមទារនៃបរិស្ថានស្អាតសំរាប់តំបន់រមណីយដ្ឋាន។ ក្រុមហ៊ុននឹងផ្តល់ធុងដាក់ សំរាមដោយឡែកៗពីគ្នា តាមប្រភេទសំរាម ដូចជា (១) ធុងសំរាមក្រដាស់/ប្លាស្ទិក/កំទេចដែក /កែវ (២) ធុងសំរាមផ្ទះបាយ និង (៣) ធុងសំរាមគ្រោះថ្នាក់(ថ្មពិល អាគុយ សំណល់ថ្នាំពេទ្យ និងសាធាតុពុល ។ល។)*<br>- *ប្រព័ន្ធប្រមូលសំរាមផ្ទះបាយមួយដងទៅពីរដងក្នុងមួយថ្ងៃនឹងត្រូវអនុវត្តចំពោះគំរោងមរកត។ ប្រើប្រាស់ឡានដឹកសំរាមដែលមានគុណភាពល្អ ដើម្បីធានាមិនឱ្យមានការលេច ឬកំពុបសំរាមតាម ដងផ្លូវឡើយ។*<br>- *ក្រុមហ៊ុនកោះពស់នឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមនៅក្នុងក្រុងព្រះសីហនុ (ដូចជា ក្រុមហ៊ុន ជីណទ្រី) ដើម្បីប្រមូល ដឹកជញ្ជូន និងយកទៅបោះចោលនូវសំណល់រឹងទាំងអស់ដែល ចេញពីគំរោងមរកត ពេញរយៈពេលប្រតិបត្តិគំរោង។* | PO | មាននៅក្នុងទុនវិនិយោគ |

<u>**ចំណាំ:**</u>

CE = វិស្វករសំណង់

DE = វិស្វកររចនាប្លង់

OE = វិស្វករប្រតិបត្តិ

MPWT = ក្រសួងសាធារណការ និងដឹកជញ្ជូន

PO = ម្ចាស់គំរោង

TSMC = គណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេស

## ៧.៣ កម្មវិធីពិនិត្យតាមដានបរិស្ថាន

ការត្រួតពិនិត្យលើសមាសធាតុបរិស្ថានដែលកើតមានឡើងដោយសារគំរោងក្នុងដំណាក់កាល មុនសាងសង់ ពេលសាងសង់ និងប្រតិបត្តិ នឹងត្រូវធ្វើជាចាំបាច់។ ស្ថាប័នទទួលខុសត្រូវ និងថវិកាសំរាប់កិច្ចដំណើរការត្រួតពិនិត្យ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីត្រួតពិនិត្យបរិស្ថានដូចមានបង្ហាញជូននៅខាងក្រោម។ ថវិកាសំរាប់ត្រួតពិនិត្យដែលត្រូវរៀបចំឡើងនេះជាបន្ទុករបស់ក្រុមហ៊ុនវិនិយោគគំរោង។ ការប៉ាន់ប្រមាណលំអិតលើការចំណាយសំរាប់កម្មវិធីត្រួតពិនិត្យបរិស្ថានមានបង្ហាញជូននៅក្នុងឧបសម្ព័ន្ធទី៨។

តារាង ៧.៣-១ : កម្មវិធីត្រួតពិនិត្យបរិស្ថាន

| វិធានការកាត់បន្ថយ | ប៉ារ៉ាម៉ែត្រពិនិត្យ តាមដាន | ទីកន្លែង | កាលវេលា តាមដាន | ស្ថាប័នទទួលខុសត្រូវ | តំលៃ, ដុល្លា US |
|---|---|---|---|---|---|
| ***ដំណាក់កាលមុនការសាងសង់*** | | | | | |
| គំរោងមរកតនឹងអនុវត្តតាមរចនាប្លង់វិស្វកម្មទាំងអស់ដែលបានយល់ព្រមដោយអន្តរក្រសួង និងរាជរដ្ឋាភិបាលកម្ពុជា។ | ពិនិត្យប្លង់វិស្វកម្មចុងក្រោយ និងការរៀបចំដាក់សមាសធាតុគំរោង ដូចការយល់ព្រមពីអន្តរក្រសួង និងរាជរដ្ឋាភិបាលកម្ពុជា។ | ការិយាល័យគំរោង | ម្តងសំរាប់ការរៀបចំពង្រាងប្លង់ចុងក្រោយ និងម្តងសំរាប់ការរៀបចំប្លង់ចុងក្រោយ | DE/PO, MPWT, MLMUPC និង TSMC | គ្មាន |
| - ការសំអាតការដ្ឋាននឹងត្រូវធ្វើតែកន្លែងដែលត្រូវការសាងសង់ចាំបាច់ប៉ុណ្ណោះ។<br>- ការពារសំណឹកដីអំឡុងពេលការងារដី។ | ពិនិត្យការអនុវត្តជាក់ស្តែង ចំពោះការសំអាតការដ្ឋាន និងការទប់ស្កាត់សំណឹកដី | នៅតាមការដ្ឋានសាងសង់នីមួយៗ | ៦ដង អំឡុងពេលការងារដី និងសំអាតការដ្ឋាន | PO, TSMC, និង PDoE | ៣០០ |
| ការពារភក់ ឬល្បប់/ផេះពី រណ្តៅខួង | ពិនិត្យការបំពុលចេញពីការខួងរណ្តៅង សំរាប់ការអង្កេតភូគព្ភសាស្ត្រ | តាមរណ្តៅខួងនិមួយៗ | ១០ដង ក្នុងអំឡុងពេលខួងសិក្សាដី | PO, TSMC, និង PDoE | ៥០០ |



Draft

| វិធានការកាត់បន្ថយ | ប៉ារ៉ាម៉ែត្រត្រូវពិនិត្យ តាមដាន | ទីកន្លែង | កាលវេលា តាមដាន | ស្ថាប័នទទួលខុសត្រូវ | តំលៃ, ដុល្លា US |
|---|---|---|---|---|---|
| *ដំណាក់កាលសាងសង់* | | | | | |
| ផ្តល់ស្លាកសញ្ញាចរាចរណ៍ និងអ្នកសំរួលចរាចរណ៍នៅតាមផ្លូវចេញចូលការដ្ឋាន | ពិនិត្យមើលគ្រឿងសំរួលចរាចរណ៍ដែលមានចែងក្នុងវិធានការ និងអង្កេតស្ថានភាពចរាចរណ៍ | នៅច្រកចូលស្ថានកោះពស់ និងនៅការដ្ឋានឆ្នេរហាវ៉ៃ | ២ដង ក្នុងអំឡុងពេលសាងសង់ | CE, TSMC និង PDoE | គ្មាន |
| ផ្តល់ទឹកស្អាត ជំរុំស្នាក់នៅ និងបង្គន់អនាម័យនៅការដ្ឋាន និងជំរុំកម្មករ | ពិនិត្យមើលស្ថានភាពជំរុំស្នាក់នៅ និងបង្គន់អនាម័យដែលបានផ្តល់ដោយគំរោង | នៅកន្លែងសាងសង់ និង ជំរុំកម្មករ | ប្រចាំត្រីមាស | PDoE | ៧៥០ |
| គ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ ទាំងនៅការដ្ឋាន និងជំរុំកម្មករ | ពិនិត្យប្រព័ន្ធគ្រប់គ្រងសំណល់ដែលផ្តល់ដោយគំរោង | | | | |
| គ្រប់គ្រងសំណល់ប្រេង និងប្រេងរំអិលចេញពីការសាងសង់គំរោង | ពិនិត្យការគ្រប់គ្រងសំណល់ប្រេង និងប្រេងរំអិល | | | | |
| ផ្តល់ឧបករណ៍ការពារសុខភាព និងគ្រឿងព្យាបាលចំពោះបុគ្គលិក-កម្មករគំរោង | ពិនិត្យមើលគ្រឿងសំភារៈការពារសុខភាពដែលផ្តល់ដោយគំរោង | នៅការដ្ឋានគំរោង | ប្រចាំត្រីមាស | CE និង PDoE | ៧៥០ |
| ដាក់ស្លាកសញ្ញាសុវត្ថិភាពជុំវិញការដ្ឋានសាងសង់គំរោង និងមានរបងស័ង្កសីជុំវិញការដ្ឋានសាងសង់ស្ពាន និងឆ្នេរហាវ៉ៃ | ពិនិត្យមើលស្លាកសញ្ញាសុវត្ថិភាពរបស់គំរោង | នៅការដ្ឋានគំរោង | ប្រចាំត្រីមាស | CE, TSMC និង PDoE | |
| ដាក់ក្រណាត់ចាប់យកកករដីនៅជុំវិញ | ពិនិត្យលើកករដីក្នុងទឹក | នៅកន្លែងសាងសង់ | ប្រចាំសប្តាហ៍ | PDoE | ៥០០ |

Draft

| វិធានការកាត់បន្ថយ | ប៉ារ៉ាម៉ែត្រត្រូវពិនិត្យ តាមដាន | ទីកន្លែង | កាលវេលា តាមដាន | ស្ថាប័នទទួលខុសត្រូវ | តំលៃ, ដុល្លា US |
|---|---|---|---|---|---|
| កន្លែងសាងសង់នៅក្នុងទឹក និងស្រះរងកករ នៅការដ្ឋានមាត់ឆ្នេរ | | ក្នុងទឹក | | | |
| គ្របក្រណាត់ពីលើសំភារៈសំណង់ ដូចជា ស៊ីម៉ង់ត៍ គ្រួស ខ្សាច់ នៅពេលដឹកជញ្ជូនវាចេញចូលការដ្ឋានគំរោង<br>ផ្សាចទឹក/ស្រោចទឹកលើគំនរខ្សាច់ គ្រួស និងផ្លូវដីក្នុងការដ្ឋានគំរោង | ពិនិត្យមើលជាក់ស្តែងលើភ្នាក់ងារអនុវត្តគំរោង ដែលបានធ្វើតាមវិធានការលំអិត | នៅការដ្ឋានគំរោង | ប្រចាំសប្តាហ៍ ក្នុងរដូវប្រាំង | PDoE | ៥០០ |
| ត្រួតពិនិត្យគុណភាពទឹកឱ្យទៀងទាត់ នៅជុំវិញការដ្ឋានសាងសង់គំរោង | ពិនិត្យមើលគុណភាពទឹកលើប៉ារ៉ាម៉ែត្រមួយចំនួន ដូចជា TSS, DO, $BOD_5$, Tot-N, Tot-P, Cd, Hg, និង Pb. | ៥ ស្ថានីយ៍ នៅក្នុងតំបន់គំរោង | ប្រចាំឆ្នាំ | DPC, PDoE | ៤.៧០០ |
| - ត្រួតពិនិត្យការបំពុលខ្យល់<br>- ម៉ោងធ្វើការពេលថ្ងៃ និងគោរពតាមកំរិតកំណត់សំលេងអតិបរមា | ធ្វើការត្រួតពិនិត្យគុណភាពខ្យល់ ប៉ារ៉ាម៉ែត្រដែលត្រូវវាស់ $NO_2$, $SO_2$, CO, TSP, និង កំរិតសំលេង | នៅកន្លែងសាងសង់របស់គំរោង | ប្រចាំឆ្នាំ | DPC, PDoE | ២.៧០០ |
| ដាំដើមឈើ ឬ រុក្ខជាតិផ្សេងៗឡើងវិញ នៅពេលមួយជាក់លាក់បន្ទាប់ពីបញ្ចប់សកម្មភាពសាងសង់តាមកន្លែងនិមួយៗ | ពិនិត្យលើអ្នកម៉ៅការបានអនុវត្តនីវិធីសាស្រ្តការពារ ដូចបង្ហាញនៅក្នុងវិធានការកាត់បន្ថយលំអិតដែរឬទេ | នៅកន្លែងទំនេរក្នុងតំបន់គំរោង | ប្រចាំត្រីមាស | FAC | ៧៥០ |

Draft

| វិធានការកាត់បន្ថយ | ប៉ារ៉ាម៉ែត្រត្រូវពិនិត្យ តាមដាន | ទីកន្លែង | កាលវេលា តាមដាន | ស្ថាប័នទទួលខុសត្រូវ | តំលៃ. ដុល្លា US |
|---|---|---|---|---|---|
| *ដំណាក់កាលប្រតិបត្តិ* | | | | | |
| - ដាក់ឱ្យបានគ្រប់គ្រាន់នូវ ភ្លើងចរាចរណ៍ ស្លាកសញ្ញាចរាចរណ៍ ភ្លើងបំភ្លឺសងខាងស្ពាន និងក្រោមស្ពាន។<br>- មានដាក់ឆ្មាំស្ពាន (សន្តិសុខ) និងប៉ូលីសចរាចរណ៍នៅលើស្ពាន | ពិនិត្យមើលតើក្រុមហ៊ុនអនុវត្តគំរោង បានដាក់គ្រឿងបំពាក់ និងឆ្មាំស្ពាន ដូចបង្ហាញនៅក្នុងវិធានការកាត់បន្ថយលំអិត ដែរឬទេ | ក្នុងតំបន់គំរោង និងស្ពានកោះពស់ | ប្រចាំឆ្នាំ | DEIA of MoE | ២៧.០០០ |
| ទូទាត់សងដល់គ្រួសារអ្នកនេសាទដែលបាត់បង់កន្លែងនេសាទក្នុងតំបន់កោះពស់ ដូចជាការ បណ្តុះបណ្តាលជំនាញថ្មី និងថវិកាទ្រទ្រង់សំរាប់ដំណើរការមុខរបរថ្មី | ពិនិត្យមើលតើក្រុមហ៊ុនអនុវត្តគំរោងបានអនុវត្តដែរឬទេ | ការិយាល័យគំរោង និងគ្រួសារអ្នកនេសាទដែលរងផលប៉ះពាល់ | ប្រចាំឆ្នាំ | | |
| ដាំដើមឈើនៅកន្លែងទំនេរ ឬ នៅតាមបណ្តោយផ្លូវ និងនៅលើកោះពស់ | ពិនិត្យមើលដើម្បីឱ្យស្របតាមផែនការសាធារណការក្រុង | នៅតំបន់គំរោង | ប្រចាំឆ្នាំ | OE, DPWT, និង FAC | ៥០០ |
| វាយតំលៃធនធានជលផល និងផ្កាថ្មនៅជុំវិញកោះពស់នៅចំងាយ ០-១គ.ម ពីមាត់ឆ្នេរ | ពិនិត្យមើលថា ការវាយតំលៃជលផល និងផ្កាថ្មត្រូវបានធ្វើតាមការបញ្ជាក់ក្នុងវិធានការពិតមែន | នៅការិយាល័យគំរោងមរកត | ជារៀងរាល់២ឆ្នាំម្តង | DEIA និង FiA | ១៣.៥០០ |
| ត្រួតពិនិត្យយ៉ាងទៀងទាត់ នូវគុណភាពទឹកនៅជុំវិញតំបន់គំរោង | ពិនិត្យមើលគុណភាពទឹកលើប៉ារ៉ាម៉ែត្រមួយចំនួនដូចជា TSS, DO, $BOD_5$, Tot-N, Tot-P, Cd, Hg, និង Pb. | ៥ ស្ថានីយ៍ នៅក្នុងតំបន់គំរោង | ប្រចាំឆ្នាំ | DPC | ៤២.០០០ |

| វិធានការកាត់បន្ថយ | ប៉ារ៉ាម៉ែត្រវពិនិត្យ តាមដាន | ទីកន្លែង | កាលវេលា តាមដាន | ស្ថាប័នទទួល ខុសត្រូវ | តំលៃ. ដុល្លា US |
|---|---|---|---|---|---|
| គ្រប់គ្រងកាកសំណល់ដែលកើតចេញពីការប្រតិបត្តិគំរោង។ ផ្តល់ធុងបែងចែកសំរាមតាមប្រភេទសំណល់ ដូចជាសំណល់ផ្ទះបាយ ក្រដាស់/ប្លាស្ទីក/ដែក និងសំណល់គ្រោះថ្នាក់ | ពិនិត្យមើលក្រុមហ៊ុនអនុវត្តគំរោងបានអនុវត្តប្រព័ន្ធគ្រប់គ្រងកាកសំណល់ ដែរឬទេ | នៅលើកោះពស់ និងឆ្នេរហាវ៉ៃ | ប្រចាំឆ្នាំ | DPC និង DEIA | ២៧.០០០ |

**ចំណាំ:**

- DE= វិស្វករប្លង់; CE= វិស្វករសំណង់; OE= វិស្វករប្រតិបត្តិ; PO=ម្ចាស់គំរោង; TSMC=គណៈកម្មការត្រួតពិនិត្យបទដ្ឋានបច្ចេកទេស;
- MPWT=ក្រសួងសាធារណការ និង ដឹកជញ្ជូន; DPWT=មន្ទីរសាធារណៈការ និង ដឹកជញ្ជូនក្រុងព្រះសីហនុ;
- MoE = ក្រសួងបរិស្ថាន ; MLMUPC = ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- PDoE=មន្ទីរបរិស្ថានខេត្តព្រះសីហនុ; DEIA=នាយកដ្ឋានអង្កេត ពិនិត្យ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន;
- FiA= រដ្ឋបាលជលផល ; FiAC= ខ័ណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ;
- FA= រដ្ឋបាលព្រៃឈើ ; FAC= ខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ;

តារាង ៧.៣-២: សង្ខេបតំលៃប៉ាន់ស្មានសំរាប់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

| បរិយាយ | តំលៃប្រចាំឆ្នាំ, USD | តំលៃសរុប, USD |
|---|---|---|
| ***ដំណាក់កាលសាងសង់*** | | |
| ការត្រួតពិនិត្យគុណភាពទឹកនៅជុំវិញការដ្ឋានតំរោង។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹក គឺ TSS, DO, BOD5, Total N, Total P, Cd, Hg, និង Pb ។ បួនស្ថានីយ៍ នឹងត្រូវជ្រើសរើស។ | ២.០៤០,០០ | ១០.២០០,០០ |
| ***ដំណាក់កាលប្រតិបត្តិ*** | | |
| ការត្រួតពិនិត្យគុណភាពទឹកនៅជុំវិញការដ្ឋានតំរោង។ ប៉ារ៉ាម៉ែត្រសំខាន់ៗសំរាប់ត្រួតពិនិត្យគុណភាពទឹក គឺ TSS, DO, BOD5, Total N, Total P, Cd, Hg, និង Pb ។ | ១.០២០,០០ | ៩១.៨០០,០០ |
| ការធ្វើអង្កេតលើធនធានជលផល និងផ្កាថ្មជុំវិញកោះពស់ (ចំងាយ ០-១គ.មពីមាត់ទឹក) គ្រោងធ្វើជារៀងរាល់២ឆ្នាំម្តង ពេញរយៈពេលប្រតិបត្តិតំរោងទាំងមូល។ | ១៥.០០០,០០ | ៦៧៥.០០០,០០ |
| **សរុប** | **១៨..០៦០,០០** | **៧៧៧.០០០,០០** |

តារាង ៧.៣-៣: សង្ខេបតំលៃប៉ាន់ស្មានសំរាប់កម្មវិធីត្រួតពិនិត្យបរិស្ថាន

| បរិយាយ | តំលៃសរុប, USD |
|---|---|
| ដំណាក់កាលមុនសាងសង់ | ៨០០,០០ |
| ដំណាក់កាលសាងសង់ | ១០.៦៥០,០០ |
| ដំណាក់កាលប្រតិបត្តិ | ១១០.៣០០,០០ |
| **សរុប** | **១២១.៧៥០,០០** |